អង្គការទស្សនៈពិភពលោក®

# កូនសៀវភៅនាទិក់វៃឆ្លាត



កម្រងសៀវភៅត្រួសត្រាយផ្លូវ

The Vanguard Series: ត្រួសត្រាយផ្លូវប្រកបដោយភាពច្នៃប្រឌិត ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងចំណាកស្រុកគ្មានសុវត្ថិភាព។

កូនសៀវភៅនាវិកឆ្លាត
© អង្គការទស្សនៈពិភពលោកអន្តរជាតិ ឆ្នាំ ២០១៤
ISBN 978-0-918261-41-0

អង្គការទស្សនៈពិភពលោក គឺជាអង្គការមនុស្សធម៌គ្រិស្តបរិស័ទមួយដែលប្តេជ្ញាចិត្តធ្វើការជាមួយកុមារ គ្រួសារ និងសហគមន៍ ដើម្បីជំនះភាពក្រីក្រ និងអយុត្តិធម៌។ ផ្អែកលើជំនឿផ្នែកគ្រិស្តសាសនារបស់យើង អង្គការទស្សនៈពិភពលោក ប្តេជ្ញាចិត្តធ្វើការជាមួយប្រជាជនងាយរងគ្រោះបំផុតរបស់ពិភពលោក។ អង្គការទស្សនៈពិភពលោក បម្រើប្រជាជនគ្រប់រូបដោយមិនប្រកាន់សាសនា ពូជសាសន៍ ឬភេទឡើយ។



# មាតិកា


តើការជួញដូរជាអ្វី? តើការធ្វើចំណាកស្រុកជាអ្វី?.............២

ច្បាប់ និងអនុសញ្ញានានាពាក់ព័ន្ធជាមួយការជួញដូរមនុស្ស.........................................................................៦

បញ្ជីផ្ទៀងផ្ទាត់៖ ចំណាកស្រុកដោយសុវត្ថិភាព................១១

គំរូនៃការសម្រេចចិត្ត........................................................១៩

បញ្ជីផ្ទៀងផ្ទាត់៖ ការធ្វើដំណើរដោយសុវត្ថិភាព................២០

បញ្ជីផ្ទៀងផ្ទាត់៖ ឯកសារសំខាន់ៗ...................................២៣

បញ្ជីផ្ទៀងផ្ទាត់៖ សុវត្ថិភាពពេលអ្នកមកដល់.....................២៨

របៀបទូរស័ព្ទត្រឡប់ទៅផ្ទះ.........................................៣១

លេខទូរស័ព្ទក្នុងគ្រាមានអាសន្ន ....................................៣៣

អ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកត្រូវបានគេជួញដូរ.................៣៦

# តើការជួញដូរមនុស្សជាអ្វី? តើការធ្វើចំណាកស្រុកជាអ្វី?

យោងតាមមាត្រា ៣ វាក្យខ័ណ្ឌ (ក) នៃពិធីសារប៉ាលីម៉ូ និយមន័យជាអន្តរជាតិរបស់ពាក្យ ការជួញដូរគឺ៖

ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ទីសំចត ឬការទទួលបុគ្គលណាមួយតាមមធ្យោបាយនៃការគំរាមកំហែង ការប្រើកម្លាំងឬការបង្ខិតបង្ខំក្នុងទម្រង់ដទៃទៀត ការបន្លំ ការបោកប្រាស់ ការរំលោភបំពានដោយប្រើអំណាច ឬស្ថានភាពងាយរងគ្រោះ ឬការផ្តល់ ឬទទួលយកកម្រៃ ឬអត្ថប្រយោជន៍នានា ដើម្បីទទួលបានការយល់ស្របពីជនណាម្នាក់ឲ្យអាចគ្រប់គ្រងលើជនណាម្នាក់ទៀតសម្រាប់គោលបំណងនៃការកេងប្រវ័ញ្ច។

ការកេងប្រវ័ញ្ចរួមមានយ៉ាងហោចណាស់ គឺការកេងប្រវ័ញ្ច ដោយពេស្យាចារលើជនដទៃ ឬការកេងប្រវ័ញ្ចផ្លូវភេទក្នុងទម្រង់ដទៃទៀត ពលកម្ម ឬសេវាដោយបង្ខំទាសភាព ឬការអនុវត្តប្រហាក់ប្រហែលទាសភាពទាសជាខ្ញុំកញ្ជះ ឬការដកហូតយកសរីរាង្គ។

ការជួញដូរមនុស្សមានធាតុផ្សំ ៣ ដូចខាងក្រោម៖

| ទង្វើ | | មធ្យោបាយ | | គោលបំណង | |
|---|---|---|---|---|---|
| ការជ្រើសរើស<br>ការដឹកជញ្ជូន<br>ការផ្ទេរ<br>ការផ្តល់ទីសំចត<br>ការទទួលយកមនុស្សណាម្នាក់ | + | ការគំរាមកំហែង<br>ប្រើកម្លាំង<br>ការបង្ខិតបង្ខំ<br>ការពង្រត់<br>ការបោកប្រាស់<br>ការរំលោភបំពានដោយអំណាច ឬដោយប្រើភាពងាយរងគ្រោះ<br>ការផ្តល់ជាថ្នូរ ឬអត្ថប្រយោជន៍ | + | ការកេងប្រវ័ញ្ចរួមទាំងពេស្យាចារលើជនដទៃ<br>ការកេងប្រវ័ញ្ចផ្លូវភេទ<br>ពលកម្មដោយបង្ខំ<br>ទាសភាព ឬការអនុវត្តប្រហាក់ប្រហែល<br>ការដកហូតយកសរីរាង្គ<br>ការកេងប្រវ័ញ្ចក្នុងទម្រង់ដទៃទៀត | = ការជួញដូរមនុស្ស |



ការជួញដូរមនុស្ស គឺជាការបោកបញ្ឆោត ឬការបង្ខំមនុស្សឲ្យធ្លាក់ចូលក្នុងទម្រង់ការងារដែលមានលក្ខណៈកេងប្រវ័ញ្ចដែលគេពិបាកក្នុងការចាកចេញ។ជារឿយៗការជួញដូរមនុស្សច្រើនពាក់ព័ន្ធជាមួយការនាំយកជនរងគ្រោះចេញពីកន្លែងដែលពួកគេរស់នៅទៅកាន់កន្លែងដទៃទៀតដោយបង្ខំ ក្នុងគោលបំណងដើម្បី **កេងប្រវ័ញ្ច**លើពួកគេ។

UNODC. 'Human Trafficking' https://www.unodc.org/unodc/en/human-trafficking/what-is-human-trafficking.html?ref=menuside.

- ការបង្ខំ៖ មនុស្សដែលត្រូវបានជួញដូរអាចត្រូវបានបង្ខំតាមវិធីផ្សេងៗជាច្រើន។ មនុស្សមួយចំនួនត្រូវបានគេបញ្ឆោតតាមរយៈការប្រាប់ថា ពួកគេនឹងទទួលបានការងារល្អពេលពួកគេទៅដល់ ហើយបន្ទាប់មកពួកគេត្រូវបានបង្ខំឲ្យធ្វើការផ្សេងមួយទៀត។ មនុស្សមួយចំនួនត្រូវបានចាក់សោរទុកនៅក្នុងរោងចក្រ ឬនៅលើទូក ហើយពុំអាចចាកចេញបាន។ មនុស្សមួយចំនួនត្រូវបានគេប្រាប់ថាអ្នកជួញដូរនឹងធ្វើអ្វីម៉្យាង អាក្រក់ចំពោះពួកគេ ឬគ្រួសារពួកគេ ប្រសិនបើពួកគេចាកចេញ។ ទាំងនេះគឺជាឧទាហរណ៍ផ្សេងៗមួយចំនួនស្ដីអំពីការបង្ខំ។
- ការបោកបញ្ឆោត៖ ពិពណ៌នាពីសកម្មភាពនៃការលាក់បាំង ឬការនិយាយភូតកុហក់ខុសពីការពិត ឬ ការនិយាយដោយមិនស្មោះត្រង់។
- ការកេងប្រវ័ញ្ច៖ ពេលជនណាម្នាក់ប្រើប្រាស់ជនដទៃ តាមធម្មតាសម្រាប់ផលប្រយោជន៍នោះ ពួកគេកំពុងកេងប្រវ័ញ្ចពីអ្នកទាំងនោះ។ ពេលមនុស្សត្រូវបានគេជួញដូរ ពួកគេប្រហែលជាអាចត្រូវបានកេងប្រវ័ញ្ចតាមរយៈការបង្ខិតបង្ខំឲ្យធ្វើការងារដែលពួកគេពុំចង់ធ្វើ បង្ខិតបង្ខំឲ្យធ្វើការ ដើម្បីទទួលបានប្រាក់កម្រៃតិចតួច បង្ខំឲ្យធ្វើការដែលទាក់ទងជាមួយផ្លូវភេទ ឬប្រហែលជាអាចត្រូវបានគេដកយកសរីរាង្គកាយទៅលក់។

**ការជួញដូរកុមារ៖** ប្រសិនបើកុមារត្រូវបានគេកេងប្រវ័ញ្ច ដើម្បីការងារផ្លូវភេទ ឬផ្នែកណាមួយនៃរាងកាយទង្វើទាំងនេះត្រូវបានចាត់ទុកថាជាការជួញដូរកុមារ។ ដើម្បីចាត់ទុកថាកុមារត្រូវបានជួញដូរ ពួកគេពុំចាំបាច់ត្រូវបង្ហាញថា ពួកគេត្រូវបានបង្ខិតបង្ខំ ឬត្រូតត្រា នោះឡើយ។ ជាការគ្រប់គ្រាន់ដោយគ្រាន់តែបង្ហាញថាមានសកម្មភាពីនរណាម្នាក់ ដើម្បីដាក់កុមារទៅក្នុងស្ថានភាពដែលមានលក្ខណៈកេងប្រវ័ញ្ចនោះគឺ ជាការជួញដូរកុមារ ហើយ។

**ចំណាកស្រុក៖** ពាក្យចំណាកស្រុកមានន័យថា ជាដំណើរ ដែលមនុស្សណាម្នាក់ផ្លាស់ទីដើម្បីទៅធ្វើការងារ។ ពាក្យជនចំណាកស្រុកសំដៅលើមនុស្ស។

# ច្បាប់ និងអនុសញ្ញានានាពាក់ព័ន្ធជាមួយការជួញដូរមនុស្ស

## សន្ធិសញ្ញាអន្តរជាតិ

### UNCRC

ក្នុងឆ្នាំ ១៩៨៩ ថ្នាក់ដឹកនាំពិភពលោកបានគ្នាក្នុងអង្គការសហប្រជាជាតិដើម្បីសរសេរអនុសញ្ញា ស្តីពីសិទ្ធិកុមារ (CRC)។ CRC រៀបរាប់អំពីសិទ្ធិដែល យុវជនក្រោមអាយុ ១៨ ឆ្នាំគួរមាន។ CRC ត្រូវបានចុះហត្ថលេខាដោយប្រទេសនានាច្រើនជាងអនុសញ្ញាដទៃទៀត។ ប្រទេសចិន ប្រទេសថៃ ប្រទេសកម្ពុជា ប្រទេសវៀតណាម ប្រទេសឡាវ និងប្រទេសមីយ៉ាន់ម៉ា សុទ្ធតែបានចុះហត្ថលេខាលើអនុសញ្ញាទាំងអស់នេះ។ ដោយហេតុថា ប្រទេសរបស់អ្នកបានចុះហត្ថលេខាលើ CRC ហើយ នោះមានន័យថាប្រទេសរបស់អ្នកបានព្រមព្រៀងថា យុវជនរស់នៅក្នុងប្រទេសទាំងនេះគួរតែមានសិទ្ធិ យោងទៅតាមអ្វីដែលមានរៀបរាប់ក្នុងសន្ធិសញ្ញានេះ។[2]

### ពិធីសារ Palermo

សន្ធិសញ្ញាអន្តរជាតិដ៏សំខាន់ដើម្បីទប់ស្កាត់ការជួញដូរគឺពិធីសារ Palermo។

---

សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅ www.unicef.org/crc/.

ឈ្មោះផ្លូវការ[2] ពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារដើម្បីបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងទៅនឹងបទឧក្រិដ្ឋឆ្លងដែន[2]។ សម្រាប់ព័ត៌មានបន្ថែមចូលទៅ www.palermprotocol.com/general/the-palerno-protocol.

ឯកសារនេះបានផ្តល់និយមន័យការជួញដូរមនុស្សថា

> ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ទីសំចត ឬការទទួលបុគ្គលណាមួយតាមមធ្យោបាយនៃការគំរាមកំហែង ការប្រើកម្លាំង ឬការបង្ខិតបង្ខំក្នុងទម្រង់ដទៃទៀត ការពង្រត់ ការបន្លំ ការបោកប្រាស់ ការរំលោភបំពានដោយប្រើអំណាច ឬស្ថានភាពងាយរងគ្រោះ ឬការផ្តល់ ឬទទួលយកកម្រៃ ឬអត្ថប្រយោជន៍នានាដើម្បីទទួលបានការយល់ស្របពីជនណាម្នាក់ឲ្យអាចគ្រប់គ្រងលើជនណាម្នាក់ទៀតសម្រាប់គោលបំណងនៃការកេងប្រវ័ញ្ច។

ពិធីសារ Palermo ត្រូវបានចុះហត្ថលេខាដោយបណ្តាប្រទេសចំនួន ១៥៥ ដោយក្នុងនោះរួមមានទាំង៖

| | |
|---|---|
| ប្រទេសកម្ពុជា | ឆ្នាំ ២០០៧ |
| ប្រទេសចិន | ឆ្នាំ ២០១០ |
| សាធារណរដ្ឋប្រជាធិបតេយ្យឡាវ | ឆ្នាំ ២០០៣ |
| ប្រទេសមីយ៉ាន់ម៉ា | ឆ្នាំ ២០០៤ |
| ប្រទេសថៃ | ឆ្នាំ ២០០១ |
| ប្រទេសវៀតណាម | ឆ្នាំ ២០១២ |

# ច្បាប់ជាតិប្រឆាំងនឹងការជួញដូរមនុស្ស

ការជួញដូរមនុស្សគឺជាបទឧក្រិដ្ឋនៅក្នុងប្រទេសកម្ពុជា ចិន សាធារណរដ្ឋប្រជាធិបតេយ្យឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ដែលសុទ្ធតែជាប្រទេសគោលដៅសម្រាប់ជនចំណាកស្រុក។

## ប្រទេសកម្ពុជា 

តាមន័យរបស់ច្បាប់ កុមារត្រូវបានកំណត់និយមន័យថាជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ក្នុងប្រទេសកម្ពុជា។

ការជួញដូរមនុស្សត្រូវបានចាត់ទុកថា ជាបទឧក្រិដ្ឋនៅក្នុងប្រទេសកម្ពុជា នៅក្រោមច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ (ឆ្នាំ ២០០៨)។ ច្បាប់នេះគ្របដណ្តប់លើទាំងបុរស និង ស្ត្រី។

ក្នុងប្រទេសកម្ពុជាការរំលោភសេពសន្ថវៈ គឺជាបទល្មើសព្រហ្មទណ្ឌ។

## សាធារណរដ្ឋប្រជាមានិតចិន 

ច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសចិនពុំមាននិយមន័យជាក់លាក់អំពីអនិតិជនឡើយ។ ក្នុងច្បាប់មួយចំនួនក្នុងប្រទេសចិន អនិតិជនត្រូវបានពិពណ៌នាថា ជាមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ ប៉ុន្តែនៅមានភាពពុំច្បាស់លាស់ថាតើចំណុចនេះត្រូវអនុវត្តក្នុងករណីនៃការជួញដូរដែរ ឬទេ។

ច្បាប់ព្រហ្មទណ្ឌរបស់សាធារណរដ្ឋប្រជាមានិតចិនចាត់ទុកការជួញដូរជាបទឧក្រិដ្ឋ។ ប៉ុន្តែច្បាប់នេះឆ្លើយតបទៅនឹងការជួញដូរស្ត្រី និងកុមារប៉ុណ្ណោះ ប៉ុន្តែមិនបញ្ជាក់អំពី

ការជួញដូរបុរសឡើយ (មាត្រា ២៩០, ២៩១, ២៦២)។
មាត្រា ២៩៩ ហាមឃាត់ការបង្ខិតបង្ខំនិយោជិតឲ្យធ្វើការដោយដាក់កំហិតលើសេរីភាពរបស់ពួកគេ។
មាត្រា ៣៥៨ និង ៣៥៩ ហាមឃាត់ពេស្យាចារដោយបង្ខំ។
មាត្រា ២៣៦ ចាត់ទុកការរំលោភសេពសន្ថវៈជាបទឧក្រិដ្ឋ។
មាត្រា ៩១៦ ដាក់បន្ទុកលើរដ្ឋក្នុងការសង្គ្រោះស្ត្រី/កុមារដែលត្រូវបានចាប់ពង្រត់។

## សាធារណរដ្ឋប្រជាធិបតេយ្យឡាវ 

ទាក់ទិននឹងការជួញដូរមនុស្ស ច្បាប់ព្រហ្មទណ្ឌឡាវកំណត់និយមន័យអនិតិជនថា ជាមនុស្សដែលមានអាយុក្រោម១៨ ឆ្នាំ។

ច្បាប់ព្រហ្មទណ្ឌឡាវ (ឆ្នាំ ២០០៩) ចាត់ទុកការជួញដូរមនុស្សថាជាបទឧក្រិដ្ឋ (មាត្រា ១៣៩)។

ច្បាប់ស្តីពីការបង្កើតការការពារស្ត្រី (ឆ្នាំ ២០០៩) ក៏ហាមឃាត់ការជួញដូរស្ត្រី និងកុមារផងដែរ ជាពិសេសគឺនៅក្នុងមាត្រា ២៩។

## ប្រទេសមីយ៉ាន់ម៉ា 

ទាក់ទងនឹងការជួញដូរមនុស្ស ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ ២០០៥) ពិពណ៌នាថាកុមារជាមនុស្សមានអាយុក្រោម ១៨ ឆ្នាំ។[៩]

ផ្នែក ៣ ក នៃច្បាប់នេះចាត់ទុកការជួញដូរមនុស្សជាបទល្មើសឧក្រិដ្ឋ។

[៩]ច្បាប់បានបែងចែករវាងកុមារ (ក្រោមអាយុ ១៦ ឆ្នាំ) និងយុវជន (អាយុ ១៦-១៨ ឆ្នាំ) ប៉ុន្តែបាននិយាយថាទាក់ទងនឹងការជួញដូរនរណាម្នាក់នៅក្រោមអាយុ ១៨ ឆ្នាំ គឺត្រូវបានចាត់ទុកថាជាអនីតិជន។

ច្បាប់ព្រហ្មទណ្ឌរបស់មីយ៉ាន់ម៉ាចាត់ទុកការរំលោភសេពសន្ថវៈជាបទល្មើសឧក្រិដ្ឋក្នុងផ្នែកទី ៣៧៥ និង ៣៥៦។

## ប្រទេសថៃ 

ផ្នែកទី៤នៃច្បាប់ប្រឆាំងការជួញដូរមនុស្ស(ឆ្នាំ២០០៨) បានកំណត់និយមន័យកុមារថា ជាជនទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ។

ផ្នែកទី ៤ និងទី ៦ ចាត់ទុកការជួញដូរមនុស្សជាបទល្មើសឧក្រិដ្ឋ។

## ប្រទេសវៀតណាម 

ច្បាប់ស្តីពីការការពារ ការថែទាំ និងការអប់រំកុមារ (ឆ្នាំ ២០០៤) កំណត់និយមន័យកុមារថា ជាជនទាំងឡាយណាដែលមានអាយុក្រោម ១៦ ឆ្នាំ។ ច្បាប់ព្រហ្មទណ្ឌវៀតណាម (ឆ្នាំ ១៩៩៩) មិនបានកំណត់និយមន័យស្តីពីអាយុរបស់កុមារឡើយ។

ការជួញដូរស្ត្រី និងកុមារ (មិនមែនបុរស) គឺត្រូវចាត់ទុកជាបទល្មើសឧក្រិដ្ឋក្នុងប្រទេសវៀតណាម ក្រោមច្បាប់ព្រហ្មទណ្ឌវៀតណាម (មាត្រា ១១៩ និង ១២០)។

ប្រទេសវៀតណាមមានច្បាប់ប្រឆាំងការជួញដូរដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១១ហើយចូលជាធរមានក្នុងខែមករា ឆ្នាំ ២០១២។ ការជួញដូរមនុស្សត្រូវបានចាត់ទុកជាបទល្មើសឧក្រិដ្ឋនៅក្រោមច្បាប់នេះ ហើយ រដ្ឋាភិបាលបានឈានជំហ៊ានដើម្បីអនុវត្តច្បាប់ថ្មីនេះ។

ការរំលោភសេពសន្ថវៈត្រូវបានចាត់ទុកជាបទល្មើសឧក្រិដ្ឋនៅក្រោមច្បាប់ព្រហ្មទណ្ឌ (មាត្រា ១១១- ១៥)។

# បញ្ជីផ្ទៀងផ្ទាត់៖ចំណាកស្រុកដោយសុវត្ថិភាព

សូមឆ្លើយសំណួរទាំងអស់នេះនៅពេលអ្នកចាប់ផ្តើមការពិភាក្សាដំបូងអំពីការផ្លាស់ទីទៅទទួលយកការងារនៅក្រៅសហគមន៍របស់អ្នក។ សូមពិភាក្សាសំណួរទាំងនេះជាមួយគ្រួសាររបស់អ្នក។

## ព័ត៌មានអំពីគោលដៅរបស់អ្នក



| បញ្ជីផ្ទៀងផ្ទាត់ | បាទ/ចាស | ទេ |
|---|---|---|
| តើអ្នកដឹងថាអ្នកកំពុងទៅទីណា ឬទេ? ប្រសិនបើដឹងសូមសរសេរឈ្មោះ ទីកន្លែងនោះនៅត្រង់នេះ៖................................... ....................................... | | |
| តើអ្នកស្គាល់នរណាម្នាក់ ដែលរស់នៅក្នុងទីកន្លែងដែលអ្នកនឹងទៅនោះ ឬទេ? | | |
| តើអ្នកមានលេខទូរស័ព្ទរបស់ជននោះ ឬទេ? | | |

| | | |
|---|---|---|
| តើអ្នកអាចទូរស័ព្ទទៅកាន់ជននោះឲ្យធ្វើគំរោងដើម្បីជួបជាមួយអ្នក ពេលអ្នកមកដល់បានដែរ ឬទេ? | | |

## ព័ត៌មានអំពីការធ្វើដំណើរ



| បញ្ជីផ្ទៀងផ្ទាត់ | បាទ/ចាស | ទេ |
|---|---|---|
| តើអ្នកដឹងអំពីរបៀបដើម្បីត្រឡប់មកប្រទេសកំណើតវិញនៅពេលការងាររបស់អ្នកបានបញ្ចប់ ឬទេ? | | |
| តើការធ្វើដំណើរត្រឡប់មកវិញចំណាយអស់ថ្លៃប៉ុន្មាន? សូមសរសេរចំនួនទឹកប្រាក់នៅទីនេះ៖......................... | | |
| តើត្រូវចំណាយថ្លៃរស់នៅអស់ប៉ុន្មានក្នុងទីកន្លែងដែលអ្នកនឹងទៅ ប្រសិនបើអ្នកពុំបានទទួលការងារពេលអ្នកមកដល់ដំបូង? សូមសរសេរចំនួនទឹកប្រាក់នៅទីនេះ៖............ ........................................................................................... | | |

| | | |
|---|---|---|
| តើអ្នកមានលុយគ្រប់គ្រាន់ដើម្បីរស់នៅមួយរយៈពេលអ្នកទើបមកដល់ដំបូង និងសម្រាប់ថ្លៃធ្វើដំណើរត្រឡប់មកវិញ ឬទេ? (សូមចងចាំថា វាជាការគ្រោះថ្នាក់ណាស់ ប្រសិនបើអ្នកត្រូវខ្ចីលុយពីឈ្មួញ ី ឬបុគ្គលិកឬនិយោជកដើម្បីធ្វើដំណើរ ឬប្រសិនបើអ្នកត្រូវខ្ចីលុយគេដើម្បី បង់ថ្លៃប្រាក់សម្រាប់អ្នកជ្រើសរើសនោះ។ ជារឿងគ្រោះថ្នាក់ណាស់ក្នុងការមកដល់កន្លែងធ្វើការថ្មីដោយជំពាក់លុយអ្នកជ្រើសរើសបុគ្គលិក ឬនិយោជក។) | | |
| តើអ្នកកំពុងធ្វើដំណើរជាមួយមិត្តភក្តិឬទេ? | | |

## ព័ត៌មានអំពីការងារ



| បញ្ជីផ្ទៀងផ្ទាត់ | បាទ/ចាស | ទេ |
|---|---|---|
| តើអ្នកមានស្គាល់នរណាម្នាក់ដែលត្រូវបានជួលឲ្យធ្វើការងារតាមរយៈមនុស្ស ឬភ្នាក់ងារជ្រើសរើសបុគ្គលិកនេះពីមុនមកទេ? | | |
| តើអ្នកដែលធ្លាប់ទទួលការងារពីមុននោះត្រឡប់មកលេងផ្ទះខ្លះ ឬទេ? | | |
| តើអ្នកដែលធ្លាប់បានទទួលការងារនោះបានទូរស័ព្ទមកកាន់គ្រួសាររបស់គាត់ ឬទេ? | | |
| តើការងារនេះស្តាប់ទៅហាក់ដូចជាការងារដទៃទៀតដែលអ្នកធ្លាប់បានលឺដែរ ឬទេ? | | |
| តើការងារនេះផ្តល់ប្រាក់ឈ្នួលដូចគ្នានឹងការងារចំណាកស្រុកដទៃទៀតដែលអ្នកធ្លាប់បានលឺ ឬទេ? (ប្រសិនបើស្តាប់ទៅហាក់ដូចជាល្អពេកហួសពីការពិតនោះប្រហែលជាការកុហក។) | | |

| | | |
|---|---|---|
| តើអ្នកដែលរៀបចំការងារសម្រាប់អ្នកនោះ ប្រាប់អ្នកអំពីឈ្មោះក្រុមហ៊ុនដែលអ្នកនឹងធ្វើការឲ្យ ឬទេ? សូមសរសេរឈ្មោះនោះនៅទីនេះ៖.......... ........................................... | | |
| តើជននោះអាចប្រាប់អ្នកអំពីអាសយដ្ឋាន និងលេខទូរស័ព្ទរបស់ក្រុមហ៊ុន ឬទេ? សូមសរសេរនៅទីនេះ៖............... ........................................... | | |

## ព័ត៌មានអំពីការងារ



| បញ្ជីផ្ទៀងផ្ទាត់ | បាទ/ចាស | ទេ |
|---|---|---|
| តើអ្នកមានស្គាល់នរណាម្នាក់ដែលត្រូវបានជួលឲ្យធ្វើការងារតាមរយៈមនុស្ស ឬភ្នាក់ងារជ្រើសរើសបុគ្គលិកនេះពីមុនមកទេ? | | |
| តើអ្នកដែលធ្លាប់ទទួលការងារពីមុននោះត្រឡប់មកលេងផ្ទះខ្លះ ឬទេ? | | |
| តើអ្នកដែលធ្លាប់បានទទួលការងារនោះបានទូរស័ព្ទមកកាន់គ្រួសាររបស់គាត់ ឬទេ? | | |
| តើការងារនេះស្តាប់ទៅហាក់ដូចជាការងារដទៃទៀតដែលអ្នកធ្លាប់បានលឺដែរ ឬទេ? | | |
| តើការងារនេះផ្តល់ប្រាក់ឈ្នួលដូចគ្នានឹងការងារចំណាកស្រុកដទៃទៀតដែលអ្នកធ្លាប់បានលឺ ឬទេ? (ប្រសិនបើស្តាប់ទៅហាក់ដូចជាល្អពេកហួសពីការពិតនោះប្រហែលជាការកុហកៗ) | | |

| | | |
|---|---|---|
| តើអ្នកអាចបើករកមើលឈ្មោះ និងអាសយដ្ឋានរបស់ក្រុមហ៊ុនតាមអ៊ីនធឺណេតបានទេ? | | |
| តើអ្នកមានកិច្ចសន្យា ឬទេ? | | |
| ប្រសិនបើមិនមានកិច្ចសន្យា តើអ្នកបានពិភាក្សាអំពីល័ក្ខខ័ណ្ឌការងាររបស់អ្នក ឬទេ? | | |
| តើអ្នកអាចអាន និងយល់ខ្លឹមសារកិច្ចសន្យាទាំងមូល ឬទេ? | | |
| តើអ្នកយល់ស្របជាមួយខ្លឹមសារទាំងអស់ដែលមានចែងក្នុងកិច្ចសន្យា ឬទេ? | | |

## ឯកសារ



| បញ្ជីផ្ទៀងផ្ទាត់ | បាទ/ចាស | ទេ |
|---|---|---|
| ប្រសិនបើអ្នកទៅកាន់ប្រទេសដទៃ តើអ្នកមានលិខិតឆ្លងដែន និងទិដ្ឋាការធ្វើការងារសម្រាប់ប្រទេសនោះ ឬទេ? | | |

## មនុស្សដើម្បីទំនាក់ទំនង



| បញ្ជីផ្ទៀងផ្ទាត់ | បាទ/ចាស | ទេ |
|---|---|---|
| តើអ្នកនឹងយកទូរស័ព្ទដៃទៅជាមួយអ្នកដើម្បីឲ្យអ្នកអាចទំនាក់ទំនងមកកាន់គ្រួសារអ្នកវិញ ពេលអ្នកទៅឆ្ងាយឬទេ? | | |
| តើអ្នកស្គាល់អង្គការ ឬមនុស្សដើម្បីទំនាក់ទំនងនៅក្នុងទីកន្លែង/ប្រទេសដទៃនោះ ឬទេ ប្រសិនបើមានអ្វីម៉្យាងមិនល្អកើតឡើង ហើយប្រសិនបើអ្នកត្រូវការជំនួយ និងសុវត្ថិភាព? ................................ | | |

សូមបន្ថែមគំនិតរបស់អ្នកនៅទីនេះ (ឧទាហរណ៍ផ្អែកទៅតាមប្រទេសជាក់លាក់)។

ចម្លើយរបស់អ្នកឆ្លើយ បាទ/ចាស កាន់តែច្រើន
បានន័យថា
ផែនការរបស់អ្នកមានសុវត្ថិភាព។

# គំរូនៃការសម្រេចចិត្ត






# បញ្ជីផ្ទៀងផ្ទាត់៖ ការធ្វើដំណើរដោយសុវត្ថិភាព

## សូមត្រួតពិនិត្យថាតើចំណុចមួយណាខ្លះដែលអ្នកបានបំពេញរួចហើយ ✔

ស្វែងរកជម្រើសសម្រាប់ការធ្វើចំណាកស្រុកដែលមាន ឯកសារត្រឹមត្រូវ។វាមានសុវត្ថិភាពជាង។

.................................................................................

សូមបំពេញបញ្ជីផ្ទៀងផ្ទាត់៖ ចំណាកស្រុកដោយសុវត្ថិ ភាព និងឯកសារសំខាន់ៗ មុនពេលអ្នកចាកចេញ។

.................................................................................

ទន្ទេញលេខទូរស័ព្ទដើម្បីទូរស័ព្ទត្រឡប់មកផ្ទះវិញពីប្រទេសថ្មីមុនពេលអ្នកចាកចេញ។

.................................................................................

ទុកសំណៅឯកសាររបស់អ្នកមួយច្បាប់ជាមួយនរណាម្នាក់ដែលអ្នកទុកចិត្តនៅផ្ទះរបស់អ្នក(ប្រសិនបើអ្នក ជួបបញ្ហា ឬបាត់ឯកសារអ្នកអាចឲ្យគ្រួសាររបស់អ្នកជួយអ្នកបាន)។

.................................................................................

សូមកាន់សំណៅឯកសារថតចម្លងជាមួយ
អ្នកឲ្យនៅដាច់ដោយឡែកពីឯកសារ
សំណៅដើម។

ធ្វើដំណើរដោយមានលុយគ្រប់គ្រាន់
សម្រាប់រស់នៅមួយ រយៈដោយ
មិនមានការងារ និងប្រាក់សម្រាប់
ត្រឡប់មកផ្ទះវិញ។

រក្សាកូនសៀវភៅអ្នកនាំផ្លូវដ៏ឆ្លាតវៃ
ជាមួយអ្នក ឯកសារ របស់អ្នក និង
លុយរបស់អ្នកនៅក្នុងកន្លែងមាន
សុវត្ថិភាពលាក់បាំងពីភ្នែកគេនៅ
ក្នុងសម្លៀកបំពាក់របស់អ្នក។



## សូមចងចាំ៖

សូមធ្វើដំណើរ ជាក្រុមជាមួយជនចំណាកស្រុកដ៏ទៃដូចរូបអ្នក (ការបោកមនុស្សច្រើននាក់ ក្នុងពេលតែមួយមានការលំបាកជាងការបោកមនុស្សតែម្នាក់ ហើយពេលអ្នកនៅជាក្រុម មានន័យថាអ្នកមានមិត្តភក្តិដើម្បីសុំឲ្យជួយ)។

ត្រូវប្រកាន់ចិត្តសង្ស័យចំពោះមនុស្សចម្លែកមុខ (ពួកគេអាចជាអ្នកជួញដូរមនុស្ស)។

សិនបើនរណាម្នាក់ព្យាយាមដាក់សម្ពាធឲ្យអ្នកប្រគល់ឯកសាររបស់អ្នកឲ្យគេសូមសួរទៅកាន់អ្នកធ្វើដំណើរដទៃទៀត ឬមន្ត្រីដើម្បីជួយអ្នក។

សូមកុំដើរតាមជនមិនស្គាល់មុខនៅស្ថានីយ៍រថភ្លើង ឬស្ថានីយ៍ឡានក្រុង។

ព្យាយាមជៀសវាងកុំចូលទៅក្នុងយានយន្តឯកជន ឬឡានទូរីស។



# បញ្ជីផ្ទៀងផ្ទាត់៖ ឯកសារសំខាន់ៗ

ខាងក្រោមនេះគឺជាបញ្ជីលេខទូរស័ព្ទ និងឯកសារដែលអ្នកគួរយកតាមខ្លួនគ្រប់ពេលវេលានៅពេលអ្នកធ្វើចំណាកស្រុក។

**សូមថតចម្លងឯកសាររបស់អ្នកចំនួនពីរច្បាប់។**

ទុកឯកសារថតចម្លងមួយច្បាប់ជាមួយគ្រួសារអ្នក ហើយយកមួយច្បាប់តាមខ្លួន។ សូមរក្សាឯកសារថតចម្លងរបស់អ្នកនៅកន្លែងផ្សេងពីឯកសារពិតប្រាកដ ធ្វើដូច្នេះប្រសិនបើក្នុងករណីឯកសារដើមបាត់ ឬត្រូវគេលួច អ្នកមានសំណៅថតចម្លងដើម្បីបង្ហាញដល់អាជ្ញាធរ។



លេខទូរស័ព្ទ ឬឯកសារដែលអ្នកគួរព្យាយាមរកឲ្យបាន សូមសរសេរលេខទូរស័ព្ទ និងអាសយដ្ឋាននៅក្នុងចន្លោះខាងក្រោមប្រសិនបើអ្នកមាន៖

លេខទូរស័ព្ទរបស់គ្រួសារអ្នក



លេខទូរស័ព្ទរបស់មនុស្សដែលនៅកន្លែងធ្វើការនោះរួចហើយ



លេខទូរស័ព្ទរបស់មនុស្សដែលអ្នកស្គាល់ដែលកំពុងរស់នៅក្នុងកន្លែងគោលដៅរបស់អ្នក



លេខទូរស័ព្ទរបស់បណ្ដាញទូរស័ព្ទជំនួយ/អង្គការក្រៅរដ្ឋាភិបាលនៅកន្លែងដែលអ្នកត្រូវទៅក្នុងករណីអ្នកត្រូវការជំនួយ។



លេខទូរស័ព្ទប៉ូលីស។



ឈ្មោះ និងអាសយដ្ឋានទីកន្លែងដែលអ្នកត្រូវធ្វើការ។



ឈ្មោះ និងអាសយដ្ឋានទីកន្លែងដែលអ្នកត្រូវធ្វើការ។



ឈ្មោះ និងអាសយដ្ឋានរបស់ស្ថានទូតប្រចាំប្រទេសអ្នកនៅក្នុងកន្លែងប្រទេសគោលដៅរបស់អ្នក។



ឈ្មោះ និងអាសយដ្ឋានរបស់អង្គការក្រៅរដ្ឋាភិបាល ដូចជា World Vision នៅកន្លែងប្រទេសគោលដៅថ្មីរបស់អ្នក។





| បញ្ជីផ្ទៀងផ្ទាត់ | បាទ/ចាស | ទេ |
|---|---|---|
| លិខិតឆ្លងដែន (ប្រសិនបើត្រូវធ្វើដំណើរទៅកាន់ប្រទេសផ្សេងទៀត)។ | | |
| ច្បាប់ថតចម្លងលិខិតឆ្លងដែន (ឲ្យទៅអ្នកដទៃតែសំណៅថតចម្លងប៉ុណ្ណោះ ជានិច្ចកាលត្រូវទុកលិខិតឆ្លងដែនរបស់ខ្លួនជានិច្ច)។ | | |
| ទិដ្ឋាការសម្រាប់ប្រទេសគោលដៅ (ប្រសិនបើត្រូវធ្វើដំណើរទៅប្រទេសផ្សេងទៀត)។ | | |
| សំណៅថតចម្លងទិដ្ឋាការ។ | | |
| សំណៅកិច្ចសន្យាការងាររបស់អ្នក។ | | |
| ទូរស័ព្ទដៃប្រសិនបើអាចធ្វើបាន។ (តាមធម្មតាអ្នកអាចរកស៊ីមកាតថ្មីសម្រាប់ទូរស័ព្ទរបស់អ្នកនៅក្នុងប្រទេសគោលដៅ។) | | |

លុយគ្រប់គ្រាន់ដើម្បីបង់ថ្លៃសំបុត្រធ្វើដំណើរត្រឡប់មកកាន់ប្រទេសរបស់អ្នកវិញ ប្រសិនបើអ្នកមានបញ្ហា។

បន្ថែមគំនិតរបស់អ្នកនៅទីនេះ។

អ្នកមានរបស់កាន់តែច្រើនក្នុងបញ្ជីនេះ បានន័យថា អ្នកនឹងកាន់តែមានសុវត្ថិភាពជាមុន។

# សុវត្ថិភាពពេលអ្នកមកដល់

## អ្វីដែលអ្នកគួរធ្វើពេលអ្នកមកដល់

សូមគូសសញ្ញា ✓ នៅពេលដែលអ្នកបានធ្វើចំណុចទាំងនេះ

ទីកន្លែង និងតំបន់ដែលអ្នករស់នៅ។ រៀនអំពីរបៀបពន្យល់ដល់អ្នកដទៃ អំពីទីកន្លែងដែលអ្នករស់នៅ។ (ការធ្វើបែបនេះនឹងជួយអ្នកអាចពន្យល់ថា អ្នកនៅត្រង់កន្លែងណា ប្រសិនបើអ្នកមានបញ្ហា)។

ទូរស័ព្ទទៅកាន់គ្រួសាររបស់អ្នកឲ្យបានឆាប់បំផុតបន្ទាប់ពីអ្នកមកដល់ (សៀវភៅមគ្គុទេសក៍អ្នកនាំផ្លូវឆ្លាតវៃរបស់អ្នកនឹងពន្យល់អំពីរបៀបទូរស័ព្ទត្រឡប់ទៅផ្ទះ)។ សូមប្រាប់អ្នកផ្ទះអំពីកន្លែងដែលអ្នកកំពុងរស់នៅ ហើយប្រសិនបើអាចធ្វើបានសូមផ្តល់លេខទូរស័ព្ទរបស់មិត្តភក្តិដែលពួកគាត់អាចតេមកអ្នកបាន។

ទូរស័ព្ទទៅកាន់ឪពុកម្តាយអ្នកឲ្យបានទៀងទាត់។ ជាការល្អ ប្រសិនបើអ្នកបានធ្វើផែនការជាមួយឪពុកម្តាយអ្នក ក្នុងការទូរស័ព្ទ ទៅរកពួកគាត់មួយដងក្នុងមួយសប្តាហ៍នៅថ្ងៃ និងម៉ោងដដែល។ នេះមានន័យថា ប្រសិនបើអ្នកបាត់ខ្លួន ហើយមិនបានទូរស័ព្ទ ពួកគាត់នឹងដឹងថា អ្នកជួបបញ្ហា។ សូមប្រាប់ពួកគេ ប្រសិនបើអ្នកមានបញ្ហាអ្វីមួយ។ សូមនិយាយប្រាប់ឪពុកម្តាយអ្នកអំពីបញ្ហាដែលអ្នកជួប។

---

ទៅមើលកន្លែងដែលអ្នកនឹងត្រូវធ្វើការ។ សម្រេចចិត្តថា តើលក្ខខណ្ឌការងារអាចទទួលយកបាន ឬទេ។

---

រក្សាទំនាក់ទំនងជាមួយជនចំណាកស្រុកដែលអ្នកបានធ្វើដំណើរមកជាមួយ។
កសាងបណ្តាញមិត្តភក្តិដែលស្ថិតនៅក្នុងស្ថានភាពដូចអ្នក។ ប៉ុន្តែចូរចងចាំថា មនុស្សជាច្រើនត្រូវបានជួញដូរដោយមនុស្សដែលពួកគេស្គាល់។

---

ដើរជុំវិញតំបន់ដែលអ្នករស់នៅ សិក្សាឲ្យដឹងអំពីទីកន្លែងរបស់ប៉ូលីស និងទីតាំងឡានក្រុង។

---

សាកសួរថាតើមានមជ្ឈមណ្ឌលសហគមន៍ ឬ អង្គការក្រៅរដ្ឋាភិបាលណាដែលផ្តល់សេវាដល់ជនចំណាកស្រុក ឬទីកន្លែងសម្រាប់ជនចំណាកស្រុកអាចជួបជុំគ្នា ឬទេ។ សូមទៅលេងកន្លែងទាំងអស់នេះ។

ប្រសិនបើអ្នកសម្រេចចិត្តបញ្ជូនលុយមកផ្ទះ សូមសួរមិត្តភក្តិរបស់អ្នកអំពីវិធីដ៏ពេញនិយមក្នុងការបញ្ជូនប្រាក់ទាំងនោះមកផ្ទះ។ មិនត្រូវផ្ញើលុយមកផ្ទះដោយដាក់ក្នុងស្រោមសំបុត្រឡើយ ព្រោះលុយនោះអាចនឹងត្រូវគេលួច។





# របៀបទូរស័ព្ទទៅផ្ទះ

ប្រសិនបើអ្នកមានទូរស័ព្ទ អ្នកគួរយកទូរស័ព្ទនោះទៅតាមខ្លួនពេលអ្នកធ្វើចំណាកស្រុក។ ប៉ុន្តែស៊ីមកាតដែលយកពីប្រទេសរបស់អ្នកនឹងមិនដំណើរការក្នុងប្រទេសដទៃឡើយ។ តាមធម្មតាអ្នកអាចទិញស៊ីមកាតបង់ប្រាក់ជាមុនថ្មីមួយសម្រាប់ទូរស័ព្ទរបស់អ្នកពេលអ្នកមកដល់ក្នុងប្រទេសថ្មី។

ប្រសិនបើអ្នកពុំមានទូរស័ព្ទទេ ប្រទេសគោលដៅជាច្រើនដូចជា ប្រទេសថៃ ឬម៉ាឡេស៊ី មានហាងកាហ្វេអ៊ីនធឺណែតដែលអ្នកអាចបង់ប្រាក់ដើម្បីទូរស័ព្ទមកផ្ទះបាន។

**ដើម្បីទូរស័ព្ទមកប្រទេសរបស់អ្នក អ្នកអាច៖**

ចុច៖ ០០១
រួចហើយ៖ ចុចលេខកូដប្រទេសរបស់អ្នក
រួចហើយ៖ លេខក្នុងប្រទេសរបស់អ្នក ដោយលុបលេខ 0 ដំបូងចេញ

០០១ + លេខកូដប្រទេស + (គ្មានលេខ 0) + លេខទូរស័ព្ទ។

ខាងក្រោមនេះគឺជាលេខកូដនៃប្រទេសផ្សេងៗ៖

ប្រទេសកម្ពុជា៖ ៨៥៥ ប្រទេសចិន៖ ៨៦
ប្រទេសឡាវ៖ ៨៥៦ ប្រទេសវៀតណាម៖ ៨៤
ប្រទេសថៃ៖ ៦៦ ប្រទេសមីយ៉ាន់ម៉ា៖ ៩៥

(សម្រាប់បុគ្គលិកប្រចាំប្រទេសរបស់ទស្សនៈពិភពលោក សូមរក្សាលេខកូដទាំងអស់ ប៉ុន្តែគូសសញ្ញាសម្គាល់លេខកូដដែលពាក់ព័ន្ធសម្រាប់ប្រទេសរបស់អ្នក។)

ឧទាហរណ៍ ប្រសិនបើលេខទូរស័ព្ទរបស់អ្នកក្នុងប្រទេសកម្ពុជា គឺ ០១២ ៨២០ ៥៩៩ នោះដើម្បីទូរស័ព្ទមកផ្ទះពីប្រទេសថៃ

អ្នកចុច ០០១ ៨៥៥ ១២ ៨២០ ៥៩៩

ឧទាហរណ៍ ប្រសិនបើលេខទូរស័ព្ទរបស់អ្នកក្នុងប្រទេសវៀតណាម គឺ ០១៨ ៩៩២២១១ នោះដើម្បីទូរស័ព្ទទៅប្រទេសវៀតណាមពីប្រទេសថៃ

អ្នកចុច ០០១ ៨៩ ១៨ ៩៩២២១១

# លេខទូរស័ព្ទជំនួយគ្រាអាសន្ន



## ប្រទេសកម្ពុជា

| | |
|---|---|
| នាយកដ្ឋានការពារកុមារ | 1280 |
| នគរបាលជាតិ៖ | 1288 |
| ភ្នំពេញ៖ | 017 276 222 |
| បាត់ដំបង៖ | 017 256 222 |
| បន្ទាយមានជ័យ៖ | 017 260 222 |
| សៀមរាប៖ | 017 258 222 |
| កំពង់ធំ៖ | 017 254 222 |
| កំពង់ឆ្នាំង៖ | 017 326 222 |

## ប្រទេសចិន

| | |
|---|---|
| 青少年维权 បណ្ដាញទូរស័ព្ទទាន់ហេតុការណ៍យុវជន | 12355 |
| 妇女维权 បណ្ដាញទូរស័ព្ទទាន់ហេតុការណ៍របស់ស្ត្រី | 12338 |
| 劳动维权 បណ្ដាញទូរស័ព្ទទាន់ហេតុការណ៍សិទ្ធិការងារ | 12333 |
| 市长热线 បណ្ដាញទូរស័ព្ទទាន់ហេតុការណ៍របស់អភិបាលក្រុង | 12345 |
| 报警热线 បណ្ដាញទូរស័ព្ទទាន់ហេតុការណ៍ប៉ូលីស | 110 |

ក្រសួងកិច្ចការស៊ីវិល (MCA) ដំណើរការមណ្ឌលផ្តល់ទីជម្រកនៅទូទាំងប្រទេសចិនដោយក្នុងនោះជនចំណាកស្រុកក៏អាចទៅរកក្រសួងនេះដើម្បីសុំជំនួយផងដែរ។

## ប្រទេសវៀតណាម

ខាងក្រោមនេះគឺជាលេខទូរស័ព្ទចំនួនបីខ្សែដែលជនចំណាកស្រុកអាចប្រើប្រាស់ដើម្បីសុំជំនួយក្នុងករណីមានអាសន្ន។

| | |
|---|---|
| បណ្ដាញទូរស័ព្ទទាន់ហេតុការណ៍ប្រឆាំងការជួញដូរ៖ | **1800 1567** |
| មជ្ឈមណ្ឌលធនធានជនចំណាកស្រុក (MRC)៖ | **(84) 3936 6633** |
| នាយកដ្ឋានស៊ើបអង្កេតបទឧក្រិដ្ឋ MPS៖ | **694 4037** |

## ប្រទេសឡាវ

**020 548 389 69**

## ប្រទេសមីយ៉ាន់ម៉ា

លេខទូរស័ព្ទបណ្ដាញទូរស័ព្ទទាន់ហេតុការណ៍ប្រឆាំងការជួញដូរមនុស្សគឺ៖

**95-67-412555**

**95-67-412666**

**95-949-555666**

**95-949-555777**

**95-949-555888**

**95-949-555999**

UNIAP,UNICEF, IOM, Save the Youth, World Vision and AFXB មានកម្មវិធីប្រឆាំងការជួញដូរមនុស្ស

## ប្រទេសថៃ

ជនចំណាកស្រុកអាចទូរស័ព្ទទៅលេខ **1300** ដើម្បីសុំជំនួយ។ ក្នុងខេត្តមួយចំនួនលេខទូរស័ព្ទទាន់ហេតុការណ៍ មានអ្នកបកប្រែដែលនិយាយភាសាប្រទេសជិតខាង។

**1191** គឺជាលេខដើម្បីទូរស័ព្ទទៅទំនាក់ទំនងប៉ូលីសប្រឆាំងការជួញដូរមនុស្ស។
**1417** គឺជាលេខសម្រាប់យុវជនទូរស័ព្ទសុំជំបូន្មាន។



# តើត្រូវធ្វើដូចម្តេច ប្រសិនបើអ្នកត្រូវបានគេជួញដូរ

- ប្រសិនបើអ្នកត្រូវបានគេផ្លាស់ទីចេញពីកន្លែងមួយទៅកាន់កន្លែងមួយទៀតដោយអ្នកជួញដូរនោះសូមផ្តោតភ្នែករបស់អ្នករកសញ្ញា ឬផ្លាកសម្គាល់នានា។ សូមព្យាយាមកំណត់ថា តើអ្នកនៅកន្លែងណា។ សម្លឹងរកមើលស្ថានីយ៍រថភ្លើង លេខផ្លូវជាតិឈ្មោះ ក្រុង ឬអគារធំៗ។ សូមចងចាំព័ត៌មានលម្អិត។ នេះមានន័យថាប្រសិនបើអ្នកអាចរកផ្លូវដើម្បីទូរស័ព្ទបាន អ្នកអាចពិពណ៌នាអំពីកន្លែងដែលអ្នកកំពុងស្ថិតនៅ។
- ប្រសិនបើអ្នកត្រូវបានគេបង្ខាំងដោយផ្ទុយពីឆន្ទៈរបស់អ្នកឲ្យធ្វើការងារដូចជាក្នុងផ្ទះបន ឬរោងចក្រនោះ សូមព្យាយាមស្គាល់ឈ្មោះ ទីកន្លែងដែលអ្នកត្រូវបានគេបង្ខាំងទុក។ ប្រសិនបើមានសុវត្ថិភាព សូមនិយាយទៅកាន់មនុស្សជុំវិញអ្នក ដើម្បីឲ្យដឹងថាតើពួកគេដឹងថាតើអ្នកកំពុងនៅកន្លែងណា ឬទេ។
- សូមចងចាំមុខរបស់អ្នកជួញដូរ។
- ប្រសិនបើអ្នកគិតថាត្រូវបានគេជួញដូរ សូមធ្វើផែនការមុនអ្នកធ្វើសកម្មភាព។ មិនត្រូវបណ្តោយឲ្យអ្នកជួញដូរដឹងថាអ្នកកំពុងគិតថា អ្នកត្រូវបានគេជួញដូរឡើយ សូមធ្វើតាមគេស្របពេលដែលអ្នកសម្លឹងរកមើលវិធីដើម្បីគេចខ្លួន។

- ប្រសិនបើអ្នកត្រូវបានជួញដូរទៅឲ្យលក់ភេទ សូមព្យាយាមបញ្ចុះបញ្ចូលបុរសឲ្យប្រើស្រោមអនាម័យ។
- សូមទូរស័ព្ទទៅកាន់លេខទូរស័ព្ទគ្រាអាសន្នដែលអ្នកមានក្នុងកូនសៀវភៅនាវិកឆ្លាត។
- ប្រសិនបើអ្នកត្រូវបានគេជួញដូរ ហើយពុំបានទទួលប្រាក់បៀវត្ស ហើយនិយោជកប្រាប់អ្នកថា ប្រសិនបើអ្នកធ្វើការមួយឆ្នាំ ឬពីរឆ្នាំទៀតអ្នកនឹងទទួលបានលុយច្រើននៅទីបំផុតនោះសូមកុំទុកចិត្តនិយោជករូបនោះ។ ជារឿយៗ អ្នកជួញដូរតែងព្យាយាមបោកបញ្ឆោតជនចំណាកស្រុកតាមវិធីនេះហើយជនចំណាកស្រុកពុំបានទទួលលុយនោះឡើយ។

